# រឿងចំលែកៗ ទាក់ទងនឹងលោកសង្ឃខ្មែរ

## ១. យាយ និងចៅ

យាយទៅវត្ត នាំចៅស្រីម្នាក់ទៅជាមួយ។ រៀបចំចង្ហាន់ថ្ងៃត្រង់រួច ស្តាប់លោកសូត្រ។ លោកទើបតែសូត្របានមួយភ្លែត ចៅឃ្លានបាយក៏កេះយាយ៖ យាយៗ ខ្ញុំខ្លានបាយ ! យាយមិនឆ្លើយតបទេ គិតតែពីស្តាប់លោកសូត្រធម៌បន្ត។ មួយសន្ទុះក្រោយមក ចៅកេះយាយម្តងទៀត៖ យាយៗ ខ្ញុំហេវបាយ ! យាយងាកលំឡក់ចៅបន្តិច ហើយក៏ស្តាប់លោកសូត្របន្ត។ ជាលើកទី៣ ចៅនិយាយខ្លាំងជាងមុន ថាឃ្លានបាយ។ យាយខឹងខ្លាំងណាស់ព្រោះចៅរំខានគាត់ស្តាប់ធម៌ ក៏ស្រែកសំឡុតចៅខ្លាំងៗថា៖
ប្រញាប់តែចង់ឆាន់ គ្រាន់តែទុកអោយលោកច្រេះច្រំហើយសិនមិនបាន...

## ២. មនុស្ស និងលោក

មានលោកមួយអង្គធ្វើដំណើរតាមកាណូត ពីភ្នំពេញទៅក្រចេះ។ ពេលទៅដល់កំពង់ផែខេត្តក្រចេះ អ្នកដំណើរចាប់ផ្តើមចុះចេញពីកាណូតបណ្តើរៗ ព្រមទាំងប្រគល់លុយថ្លៃធ្វើដំណើរដល់ពូ កាណូត។ លោកមិនបានដឹងតំលៃធ្វើដំណើរក៏សួរទៅពូកាណូតថា៖ ញោមៗ អស់ថ្លៃប៉ុន្មាន?ពូកាណូតសំលឹងមុខលោក បែបស្រឡាំងកាំង ហើយឆ្លើយថា៖
បើមនុស្សយកថ្លៃ បីពាន់រៀល តែបើលោកមិនដឹងយកប៉ុន្មានទេ!
លោកក៏ហុចលុយអោយបីពាន់ភ្លាម ដោយមិនបង្អង់ព្រោះខ្លាចគេថា មិនមែនមនុស្ស។

៣.